# កូន
# ឈ្លូសសម្លាប់ខ្លា



# កំសាន្តសិក្សា

## ថ្នាក់ទី ១១ និង ១២


និពន្ធដោយ : ត្រាន់ ខុនយោង

វិចិត្ររូបភាពដោយ : ជួន សម្បត្តិ


សៀវភៅសិក្សាដ៏ល្អទំនើបគឺ

« សំបូរ និង សួណារៀនអាន »

ថ្នាក់ទី ១២ ប្រកាសក្រសួងអប់រំជាតិ

លេខ 3823/73 ចុះថ្ងៃទី 26-12-73


បណ្ណាគារ ពន្លឺវិជ្ជា

លេខ ៤០៤ វិថីកម្ពុជាក្រោម ភ្នំពេញ

ល្ងាចថ្ងៃសៅរ៍ ក្រោយពេលបាយរួច សូណានិយាយ
រឿង « កូនឈ្លូសសម្លាប់ខ្លា » ជូនប៉ាវាស្តាប់ ។





ឈ្លូសមេមួយមានកូនបី ។ កូនទីមួយឈ្មោះ ឈ្លូសបង ។
កូនទីពីរឈ្មោះ ឈ្លូសប្អូន ។ កូនទីបីឈ្មោះ ឈ្លូសពៅ ។
ឈ្លូសទាំងបួនរស់នៅក្នុងព្រៃយ៉ាងសុខសាន្ត ។
ឈ្លូសមេនិយាយថា : " ម៉ែចាស់ហើយ ម៉ែចង់រកកន្លែង
ស្ងាត់ដើម្បីសម្រាក ។ ចូរកូនរកស៊ីដោយខ្លួនឯងចុះ" ។

ឈ្លូសបងខ្ជិលណាស់ ។ នៅពេលម្តាយវាឱ្យចំណី វាមិនដែលនិយាយថាអរគុណឡើយ ។

ថ្ងៃមួយវានិយាយទៅកាន់ប្អូនៗថា : « ឥឡូវបងចង់សង់ផ្ទះមួយ ។ ចូរឈ្លូសប្អូនទៅរកឈើ-វល្លិមក ។ ឯឈ្លូសពៅទៅរកកាប់ស្លឹកត្នោតនិងឫស្សីមក » ។





នៅពេលធ្វើការ ឈ្លួសបងឥតជួយធ្វើអ្វីទាំងអស់ ។
ឈ្លួសពៅខំជីករណ្ដៅ ។ ឯឈ្លួសប្អូនដាំបង្គោល ។
ឈ្លួសទាំងពីរខំធ្វើការ ពុំហ៊ានសម្រាកឡើយ ។



ឈ្លូសពៅ យកស្លឹកប្រក់
ដំបូលផ្ទះ ។
ឯឈ្លូសបង អង្គុយធ្វើ
ព្រងើយ ។
មិនយូរប៉ុន្មាន ផ្ទះមួយបាន
សង់ហើយស្រេច ។
ឈ្លូសបង ចូលក្នុងផ្ទះដេក
ធ្វើបែបហី ។ វាគ្មាន
និយាយអរគុណ ទៅរក
ប្អូនៗឡើយ ។



ចំណែកឈ្លូសប្អូនក៏បានសង់ផ្ទះមួយដែរ ។ វាហៅឈ្លូសពៅឱ្យជួយធ្វើការ ។

លុះផ្ទះសង់រួចហើយ ឈ្លូសប្អូនបណ្តេញឈ្លូសពៅឱ្យចេញក្រៅ ។ វាទាញទ្វារបិទហើយចូលដេកធ្វើព្រងើយ ។

ឈ្លូសពៅបើកភ្នែកធំៗ ហាក់ដូចស្រឡាំងកាំង ។



ឥឡូវនេះ ឈ្លួសពៅចាប់សង់ផ្ទះវាម្តង ។ គ្មាននរណា
ជួយធ្វើការឱ្យឈ្លួសពៅឡើយ ។

ឈ្លួសពៅប្រឹងធ្វើការណាស់ ។ ផ្ទះវាសង់អំពីឈើ
យ៉ាងមាំហើយល្អផង ។

ឈ្លួសពៅស្លូតណាស់ហើយសុភាពផង ។ នៅពេល
ម្តាយឱ្យចំណី ឈ្លួសពៅនិយាយ « អរគុណ » ជានិច្ច ។



ថ្ងៃមួយខ្លានិយាយថា : « កូនឈ្លូសទាំងបីធំអស់ហើយ ។
អញត្រូវទៅចាប់ឈ្លូសទាំងនោះយកមកធ្វើអាហារ » ។
ខ្លាកាន់ដំបងធំមួយ ដើរសំដៅផ្ទះឈ្លូសបងមុនគេ ។



ខ្លាដើរមកកាន់តែជិត ។ ឈ្លូសបងភ័យរញ្ជួរញ័រ ស្រែកហៅម្ដាយឱ្យជួយ ។ ប៉ុន្ដែគ្មាននរណាមកជួយវាបានឡើយ ។





ខ្លានិយាយថា : « ឱ្យអញចូលផ្ទះនេះលេងផង ! » ។

ឈ្លូសបងនិយាយថា : « ទេ! មិនបានទេ » ។ ខ្ញុំឥត ត្រូវការបងខ្លាឯងទេ ។ ម្ដាយខ្ញុំប្រាប់ថាបងខ្លាឯងស៊ីខ្ញុំ » ។

ខ្លានិយាយថា : « បើឯងមិនបើកទ្វារនេះទេ អញកំទេច ផ្ទះឯងឥឡូវហ្នឹង ! » ។

និយាយមិនទាន់ផុតផង ខ្លាលោតទាំងកំរោលកំទេច ផ្ទះឈ្លូសបង រលំគ្រាំង ។ ខ្លាចាប់ឈ្លូសបងញាត់ចូលក្នុង ស្បោង ។

ខ្លាដើរទៅរកផ្ទះឈ្លូសប្អូនទៀត ។ ឈ្លូសប្អូនឃើញដូច្នោះភ័យរញ្ជីររញ្ជ័រ ។

ខ្លាស្រែកពីចម្ងាយឱ្យឈ្លូសប្អូនបើកទ្វារ ។ ប៉ុន្តែឈ្លូសប្អូនពុំបើកទ្វារឡើយ ។ វាពួនសំងំឈឹង ។

ខ្លាខឹងណាស់ ក៏លោតសង្គ្រុបបំផ្លាញផ្ទះឈ្លូសប្អូនបាក់ខ្ទេចខ្ទីអស់ ។ ខ្លាក៏ចាប់ឈ្លូសប្អូនដាក់ស្បោងហើយដើរទៅរកផ្ទះឈ្លូសពៅទៀត ។



ខ្លាដើរមកដល់មុខផ្ទះឈ្លូសពៅ ។ ឈ្លូសពៅស្ទុះទៅបិទទ្វារ បិទបង្អួចជិត ។

ខ្លាហៅឈ្លូសពៅឱ្យបើកទ្វារ ។ ប៉ុន្តែឈ្លូសពៅពុំបើកឡើយ ។

ខ្លាក៏លោតទន្ទ្រាំផ្ទះឈ្លូសពៅពេញទំហឹង ។ ផ្ទះឈ្លូសពៅមិនរលំឡើយ ។ ទន្ទ្រាំហើយទន្ទ្រាំទៀត ផ្ទះឈ្លូសពៅមិនរលំឡើយ ។



ខ្លាក្រឡេកមើលលើ ឃើញបំពង់បង្ហុយផ្សែងមួយ ។ វាក៏ចូលតាមបំពង់ផ្សែងនោះ ដើម្បីចាប់ឈ្លូសពៅ ។

ឈ្លូសពៅឃើញដូច្នោះ ក៏ស្ទុះទៅដុតភ្លើងពីក្រោម ។

ភ្លើងឆាបឆេះរោលពេញខ្លួនខ្លា ។ មួយរំពេចនោះ ខ្លាក៏ប្រកាច់ងាប់ភ្លាមទៅ ។



លុះខ្លានោះងាប់ហើយ ឈ្លួសពៅហៅឈ្លួសបង និង ឈ្លួសប្អូនឱ្យចេញពីស្បោង ។ ឈ្លួសពៅប្រាប់ថា : « ផ្ទះខ្ញុំមាំណាស់ ខ្លាពុំអាចកំទេចផ្ទះខ្ញុំបានឡើយ ។ ឥឡូវខ្ញុំសម្លាប់ខ្លាបានហើយ » ។

ឈ្លួសបងនិង ឈ្លួសប្អូនឮដូច្នោះ ត្រេកអរយ៉ាងខ្លាំង ។ គេស្ទុះចេញពីស្បោងយ៉ាងប្រញាប់ ។ ចាប់តាំងពីពេលនោះមកឈ្លួសទាំងពីរខំប្រឹងធ្វើការណាស់ ។ គេលែងខ្ជិលទៀតហើយ ។

លុះនិយាយរឿងនេះចប់ ប៉ាសូណាប្រាប់សូណាថា : « ចូរកូនចូលគេងចុះ ព្រោះយប់ជ្រៅហើយ ! ប៉ាសប្បាយចិត្តណាស់ដោយឃើញកូនចេះនិយាយរឿងបានពិរោះដូចនេះ » ។



ចូរសរសេរឈ្មោះរូបខាងក្រោម
ហើយអានរូប ( ទី១ នឹង ទី២) ( ទី២ នឹង ទី៣) ( ទី៤ នឹ ង ទី៥



※ ចប់ ※

---

## ក្រោកពីព្រឹក

គេងក្រោកពីព្រឹក ហាត់ប្រាណងូតទឹក ឱ្យបានមុនគេ
សូត្រសាកមេរៀន កុំនៅទំនេរ រួចហើយរិះរេ
រៀបចំទៅរៀន ។

ធ្វើបានដូច្នេះ កុមារនឹងចេះ ប្រាជ្ញាក៏មាន
ម៉ាក់ប៉ាស្រលាញ់ លោកគ្រូរាប់អាន មិត្តទាំងប៉ុន្មាន
មិនហ៊ានមើលងាយ ។

ស្រង់ចេញពីទស្សនាវដ្ដីគ្រូបង្រៀន ( ក - ភ័ព្វ )

សៀវភៅជាភាសាខ្មែរនេះបោះពុម្ពឡើងវិញដោយអង្គការគាំពារកុមារខ្មែរ ក្រោមជំនួយឧបត្ថម្ភមូលនិធិដោយក្រុមហ៊ុនអារីសាវ៉ា
ក្នុងខែសីហា ឆ្នាំ២០១៧ (លើកទី៧)

Khmer edition is publied by Caring for Young Khmer
with the financial assistance of Arisawa Manufacturing Co., Ltd. in August 2017 (7th printing)

| | | |
|---|---|---|
| ចំនួន | : | ៣៥០ក្បាល |
| លេខ | : | CYK N១០០២៧ |
| រោងពុម្ព | : | JSRC |

| | | |
|---|---|---|
| Circulation | : | 350 copies |
| Book Number | : | CYK N10027 |
| Printing house | : | JSRC |

9 789996 317149